ឧប សៅ សង្ហា

# គំនិតជាតិនិយមសាកល
# និង នៅស្រុកខ្មែរ



និមិត្តរូបនៃប្រជាជាតិបារាំង

**ការសាកល្បងពិចារណា អំពីគំនិតនយោបាយ**

## មាតិការឿង

គំនិត នៃជាតិនិយម 1
គំនិត ស្នេហាជាតិ 9
គំនិតជាតិនិយម អាឡឺម៉ង់ និង បារាំង 11
គំនិតជាតិនិយម និង ស្នេហាជាតិ នៅស្រុកខ្មែរ 16

និព័ន្ធដោយ ឧប សៅ សង្ហា
ខែ មេសា ឆ្នាំ ២០១៨



និមិត្តរូបនៃប្រជាជាតិបារាំង

# គំនិត នៃជាតិនិយម

ជាតិនិយម ជាមនោគមវិជ្ជា - នៅក្នុងលំដាប់ណា ដែលគេ ឱ្យនិយមន័យវាដូចជា គំនិត ដែលបានចូលរួម ក្នុង នយោបាយ នៅទីកន្លែងណាមួយ ក្នុងពិភពលោក។ គេ សង្កត់ទៅលើសារៈសំខាន់ នៃប្រជាជាតិ នៅក្នុងការវិវត្តន៍ នៃប្រវត្តិសាស្ត្រ និង ជីវិតភាពនយោបាយ ដោយប្រកាស ថា លក្ខណៈជាតិ ជាកត្តាសំខាន់ នៃភាពខុសគ្នា នៃមនុស្ស លោក។ រុញទៅខ្លាំងទៀត, ជាតិនិយម រួមបញ្ចូលថា បុគ្គល ទាំងឡាយ មានអារម្មណ៍ថា ខ្លួនជាសមាជិក នៃប្រជាជាតិ តែមួយគត់ មុនទុកខ្លួនជាសមាជិក នៃក្រុមតូចធំណា មួយ ហើយ រៀបចំខ្លួនរួចស្រេចនឹង ធ្វើពលកម្មចាំបាច់ ដើម្បីការពារ ផលប្រយោជន៍ នៃប្រជាជាតិខ្លួន។ ជាតិនិយម រហូតទាមទារថា សញ្ជាតិនីមួយៗ ត្រូវមានការ រៀបចំច្បាស់លាស់ នៅក្នុង រដ្ឋអធិបតេយ្យមួយ។ ជាតិនិយមជាច្រើន ជាបឋម ជាគោលការណ៍ នយោបាយ ដែល អង្គភាពនយោបាយ និង អង្គភាពជាតិ ត្រូវតែផ្គាប់គ្នា។ អារម្មណ៍ជាតិនិយម គឺជាអារម្មណ៍ នៃកំហឹង ដែលបណ្តាលមកពី ការឈ្លានពាន នៃគោលការណ៍នេះ ឬ អារម្មណ៍ នៃការពេញចិត្ត បណ្តាលមកពីការធ្វើអោយវាសំរេចបាន។ ចលនាជាតិនិយម វាជារស្មីចេញពី អារម្មណ៍ទាំងពីរនោះ។

និព័ន្ធដោយ ឧប សៅ សង្ហា
ខែ មេសា ឆ្នាំ ២០១៨

ការណ៏នេះ វាពាក់ព័ន្ធនឹងការទុក ចលនាជាតិនិយម ត្រូវតែជា ចលនានៃអបគមន៍ បើសិនជាទុកថា សញ្ជាតិមួយ វាស្ថិតទាំងស្រុង នៅក្នុងព្រំដែន នៃរដ្ឋមួយផ្សេងទៀត និង ត្រូវធ្វើការកំណត់ជាថ្មី នៃភាពស្មុគស្មាញ បន្ថែមទៀត លើសពីព្រំដែន នៃរដ្ឋ បើប្រសិនជា ក្រុមសញ្ជាតិមួយ រស់នៅក្នុងរដ្ឋជាច្រើន។

ទោះជា សាស្ត្រាចារ្យមហាវិទ្យាល័យខ្លះ វាយតម្លៃថា លក្ខណៈពិសេស នៃជាតិនិយម គឺ ការទាមទារ ឯករាជ្យ, គំនិតបញ្ញាជនបែបនេះ គឺគ្មានភាពសមហេតុផល ព្រោះដូចជាការទុក ផល ជា ហេតុតែម្តង។ ចលនាជាតិនិយម បញ្ជាក់សំខាន់ថាខ្លួនជា អ្នកតំណាង នៃក្រុមសញ្ជាតិមួយ នៅក្រោមផលប្រយោជន៍ នៃសម្ភារៈ និង វប្បធម៌ ដែលសមាជិក នៃក្រុមនោះ គេរួមចំណែកគ្នា។ គេ សុំអោយបក្សពួកគេ ដាក់ខ្លួនចំណុះ នៅចំពោះមុខផលប្រយោជន៍រួម (តួយ៉ាង ផ្អែកលើ ថ្នាក់សង្គម, សាសនា, គណបក្ស), ដែលបុគ្គលម្នាក់ៗមានចំណែក ជាជនជាតិរួម ទោះបីជនទាំងឡាយនោះ ស្ថិតនៅក្រុមផ្សេងៗគ្នា តែមាន សញ្ជាតិដូចគ្នា។ តួយ៉ាង ពួកអ្នកជាតិនិយម អៀរឡង់ គេដាក់មួយឡែកសិន នូវការបែងចែកជា ពួកអ្នកសេរីនិយម និង ពួកអ្នកអភិរក្សនិយម ដើម្បីនឹងនាំគ្នា ការពារផលប្រយោជន៍ពិសេស នៃជាតិសាសន៍ អៀរឡង់។

ចលនាជាតិនិយម ភាគច្រើន គាំ ឯករាជ្យភាពជាតិ នៅក្នុងកម្មវិធីនយោបាយ, តែបើបដិសេធ ចំពោះអ្នកដទៃដែលគេ មិនធ្វើការគាំតាមខ្លួន គឺអាចនឹងទុកជាការបំពាន ដល់សេរីភាពដែរ។ ជាការពិត លើសពីនេះទៀត វាមិនជាងាយស្រួលនឹង កំណត់ នៅក្នុងលំដាប់បែបណាមួយទុកការទាមទារ នៃឯករាជ្យ ដើម្បីជានា ដល់សម្បទានផ្សេងៗ ដែលមាន នៅក្នុងស្ថានភាព គ្មានឯករាជ្យ។ ក៏ប៉ុន្តែការទាមទារជាផ្លូវការ របស់ចលនាជាតិនិយមជាច្រើនដែរក៏មិនបញ្ចូលជានិច្ច នៃការទាមទារ ឯករាជ្យនោះដែរ ដ្បិតអ្នកដឹកនាំ គាត់វាយតម្លៃថា ដើម្បី ធ្វើល្អ អោយបានសម្រេច នូវគោលដៅចុងក្រោយ ត្រូវតែភ្ជង់សិន ទៅលើមធ្យោបាយមធ្យម ដែលវានឹងអាច ធ្វើអោយកើន នូវស្វ័យភាពនយោបាយ។

ការវិភាគ លើជាតិនិយម ខាងលើនេះ គេអាចទុក សញ្ជាតិជាគំនិតសំខាន់។ រីឯ ការទាមទារ ស្វ័យភាពនយោបាយ និង ឯករាជ្យ វិញ ជាមធ្យោបាយ នៃការបន្ត នៃគោលដៅជាតិនិយម ឋិតនៅលើ ការអោយតម្លៃ លើផលប្រយោជន៍សម្ភារៈ និង វប្បធម៌ រួម របស់ជនទាំងឡាយ ដែលមានសញ្ជាតិដូចគ្នា។ នៅក្នុងរដ្ឋឯករាជ្យ វាមានដោយធម្មជាតិជាមធ្យោបាយ ព្រោះវា បង្កើនជាអតិបរមា នូវពលានុភាពរបស់ពួកអ្នកតំណាង នៃប្រជាជាតិ, តែឯករាជ្យនោះ វាត្រូវ

មានតម្លៃសេដ្ឋកិច្ចជាកូនប្រយោល ទើបអាចរក្សាវាបាន។ ចលនាជាតិនិយមណាមួយ ដែលគ្រាន់តែទាមទារ នៅក្នុងកំរិតខ្ពស់ នូវស្វ័យភាពនយោបាយ (រួមទាំង ការត្រួតត្រា នៃប្រព័ន្ធអប់រំ និង បរិធានវប្បធម៌) រួមជាមួយសម្បទានសេដ្ឋកិច្ច នៅទីកន្លែង ជាច្រើននៅក្នុងដំបន់ នៅតែទុកជា ចលនាជាតិនិយមជានិច្ច ទោះបីមិនយកការទាមទារឯករាជ្យ ជាគោលដៅដាច់ខាត។

គេទទូចជាខ្លាំងលើគំនិតថា ចលនាជាតិនិយម ត្រូវតែស្វែងរកឯករាជ្យ ដោយផ្អែកលើការអះអាង របស់សាស្ត្រាចារ្យមហាវិទ្យាល័យមួយចំនួន ថ្លែងសេចក្ដីថា « ការធានាតែមួយគត់ នៃការរស់រានមានជីវិតនយោបាយបាន នៅក្នុងលក្ខខណ្ឌទាំងឡាយ ក្នុងពិភពលោកទំនើប គឺស្ថិតនៅត្រង់ ការការពារខ្លួនអ្នក ពីអន្ដរាគមន៍ មកពីខាងក្រៅ ដែលជា សត្រូវ ជាអង្គការនយោបាយដោយឡែក ឬ រដ្ឋ »។ ការអះអាងមួយទៀត ផ្អែកលើការវាយតម្លៃ ដាក់កំរិតក្រៃពេក លើសមត្ថភាព នៃរដ្ឋទាំងឡាយ ដើម្បីសម្របទម្រង់ខ្លួន បញ្ចូលទៅក្នុង សេចក្ដីប្រាថ្នា នៃជាតិនិយម។ ដូចមានជាឧទាហរណ៍ នៅប្រទេសប៊ែលហ្ស៊ិក ដែលជា រដ្ឋមជ្ឈការ តែបានប្រែក្លាយខ្លួន ក្នុងរយៈពេលតែចតុត្ថៈនៃសតវត្ស ទៅជា រដ្ឋពីរនៃជាតិនិយម ដើម្បីសម្របទៅតាមសេចក្ដីប្រាថ្នា នៃពួកអ្នកជាតិនិយម។

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ខែ មេសា ឆ្នាំ ២០១៨**

ជាតិនិយម ទុកជាគោលលទ្ធិ នៃការអនុវត្តន៍ជាសាកល ចង់អោយជនទាំងឡាយ សំដែង នូវភក្តីភាពខ្លួន ចំពោះ ប្រជាជាតិខ្លួន : ជាជន នៃប្រជាជាតិ គឺជាទ្រព្យដ៏បវរ នៃមនុស្សម្នាក់ៗ ហើយ គំនិតជាតិនិយម វាអាចមានរូបពិសេស ចំពោះជនម្នាក់ៗ។ បន្ទាប់ពីរូបពិសេសនេះ អារម្មណ៍ នៃជាតិនិយម វាអាចស្ថិតនៅលើ ការបន្តការពារ នៃផលប្រយោជន៍ជាតិដាច់ខាត លើផលប្រយោជន៍ប្រទេសដទៃ ដោយមិនគិតពីតម្លៃផ្សេងៗទៀត - ដូចយ៉ាង គោលដៅដើម្បី វៀរចាក នៃការបង្ហូរឈាម, ថែរក្សាសហការអន្តរជាតិ តាម កតិកាសញ្ញាទ្វេភាគី ឬ ពហុភាគី។ ជាតិនិយមពិសេសបែបនេះ ទ្រទ្រង់ គំនិតអត្តទត្តភាព នៃគំនិតជាតិនិយមសាកល គឺការបន្ត រកផលប្រយោជន៍ផ្ទាល់ខ្លួន ដោយមិនគិតរវល់ ពីផលប្រយោជន៍អ្នកដទៃ, ហើយ ទុកទង្វើនេះ ជា សិទ្ធិពេញច្បាប់ របស់ខ្លួន។ ចក្រពត្រនិយម ជារូបន្តរ (variante) នៃជាតិនិយម ព្រោះវាផ្តល់នូវភាពពេញសិទ្ធិ នៃការច្បាំងដណ្តើមប្រទេសដទៃទៀតមកដាក់ជាប្រទេសចំណុះ។

ជាតិនិយម ជាមនោគមវិជ្ជា ផ្តល់ នូវចម្លើយពិសេស លើសំនួរ អំពីមូលដ្ឋានគ្រឹះ នៃការសេពគប់ របស់មនុស្ស។ ឧទាហរណ៍ជាក់ស្តែង មាននៅក្នុងលទ្ធិម៉ាក្សនិយមបវេណី ដែលមានសេចក្តីថា « អ្នកធ្វើការ គ្មានមាតុភូមិឡើយ »។

(ទ្រឹស្តី អំពីប្រវត្តិ លោក ម៉ាក្ស វាពិតជាបំណុលបញ្ញា ចំពោះ ជាតិនិយម នៅក្នុងលំដាប់ណា ដែលជាតិនិយម យក គំនិត លោក Hegel ដែលលោក បានថ្លែងថា តួអង្គ សមូហភាពទាំងឡាយ ជាកម្លាំង រុញច្រានប្រវត្តិសាស្ត្រ អោយដើរទៅមុខ តែវាក៏ធ្វើអោយដូរ នូវអត្តសញ្ញាណ នៃ សមូហភាព ពីលក្ខណៈជាប្រជាជាតិ ទៅជា វណ្ណៈសង្គម)។ ជាតិនិយម វាមានទំនាស់នឹង លទ្ធិមួយ ដែលគេអោយ ឈ្មោះថា បុគ្គលនិយម (personnalisme) ដែលបុគ្គលនិមួយៗ អាចមានជម្រើស ជ្រើសយកអំពើក្បត់ជាតិ និង ក្បត់ មិត្តរបស់ខ្លួន។ លោកសម្ព័ន្ធនិយម (cosmopolitisme) វា ប្រឆាំងនឹង បុគ្គលនិយម ដោយសម្គាល់ តាមការប្រាស័យ ទាក់ទងផ្ទាល់ខ្លួនដ៏សំខាន់ នៃមនុស្ស និង បដិសេធ នូវ កាតព្វកិច្ចទូទៅ។ តាមលោកសម្ព័ន្ធនិយមគឺ ផលប្រយោជន៍ នៃមនុស្សទាំងឡាយ វាមានគោលការណ៍ ផ្តល់សារៈ សំខាន់លើបុគ្គលម្នាក់ៗ មានភាពស្មើគ្នា។ ជាការច្បាស់ ណាស់ នៅក្នុងគោលការណ៍នេះ វាធ្វើអោយ លោកសម្ព័ន្ធ និយម ជំទាស់នឹង បុគ្គលនិយមផង និង ជាតិនិយមផង។

ជាមួយគ្នា, ជាតិនិយម អាចបង្រួប ក្នុងការប្រតិបត្តិ ជាមួយនឹង មនោគមវិជ្ជា នៃសេរីនិយម, សង្គមនិយម ឬ កុម្មុយនិស្ត ទោះបី មនោគមវិជ្ជាទាំងនោះ មានភាពខុស គ្នាពីការអនុវត្តរបស់ខ្លួន។ ជាការពិត ជាតិនិយម ជា

គោលលទ្ធិ រីកសាយជាងគេនៅក្នុងពិភពលោក ព្រោះថា គោលលទ្ធិផ្សេងៗទៀត កាន់កាប់កន្លែងមិនបានចិតថេរ នោះឡើយ ព្រោះមិនបាន បញ្ជាក់អោយបានច្បាស់លាស់ នូវឧត្តមគតិជាតិ។

អក្សរសាស្ត្រ អំពីជាតិនិយមជាច្រើន បានក្រងរូបឡើងពីការប៉ុនប៉ង ដើម្បី ចំណាត់ថ្នាក់ នូវសញ្ជាតិ ជាប្រភេទ នៃគោលគ្រឹះ ដែលប្រវត្តិសាស្ត្រ បានចែកអោយ។ បំណែកសំខាន់ វាស្ថិតនៅក្នុង វិធីសាស្ត្រនៃគោលដៅ ដែលទុកសញ្ជាតិ ជាអង្គហេតុជម្មជាតិ ផ្សំគ្នាដោយ ភាសា នឹង បច្ឆាញ្ញាតិដើម (descendance ethnique) ។ល។ និង ចក្ខុវិស័យនៃអត្តវិស័យ (vision subjectif) ដែលទុក សញ្ជាតិ ជាបាតុភូតផ្លូវចិត្ត។ ទស្សនៈចុងក្រោយនេះ បញ្ជាក់បន្ថែមថា ជាតិនិយម មានលក្ខណៈសម្បត្តិ តាមមនោសញ្ចេតនានៃភាពនៅរួមក្នុងសហគមន៏ ជាងលក្ខណៈសញ្ញាតិពិសេសដាច់ឡែក។

របៀបបកស្រាយផ្សេងៗទៀត នៃទស្សនៈទី១ វារលាយបាត់អស់នៅក្នុង ទេវកថានៃប្រវត្តិសាស្ត្រ (mythe historique) និង ជីវសាស្ត្រមិនពិត (speudobiologie)។ តែទស្សនៈទី២ វាល្អមនឹង យល់បានអំពី សមត្ថភាព នៃការតម្រូវតាម

និងការប្រែប្រួលផ្លាស់នូវអត្តរស់ នៃសញ្ញាតិ នៅក្នុងប្រជាជាតិមួយ។




និមិត្តរូបនៃសេចក្តីស្នេហាជាតិអាមេរិច

# គំនិត ស្នេហាជាតិ

ស្នេហាជាតិ វាពាក់ព័ន្ធនឹងការសម្រេចចិត្តរួចស្រេច នូវការការពារ មាតុភូមិ និង ទុកផលប្រយោជន៍ជាតិ ជាធំ។

ដូច្នេះ ស្នេហាជាតិ វាមានការយល់ច្រឡំជាមួយជាតិនិយម តែគំនិតស្នេហាជាតិ វាមានចំណាស់ជាង គំនិតជាតិនិយម ហើយវាមាន សម្បត្តិទ្រឹស្តី ច្រើនទៀតផង។ ជាតិនិយម សន្មត់ជាមុនថា ប្រទេសជា អង្គភាពជាក់ស្តែង និង ច្បាស់លាស់ ; រីឯ ស្នេហាជាតិ វិញ វាអាចគ្រាន់តែជាការជំពាក់ចិត្ត ទៅលើដំបន់មួយ, កន្លែងមួយ ឬ លំនាំ នៃជីវិតមួយ និង មិនចាំបាច់បញ្ចូល គំនិតអរូបី នៃប្រទេស។

ស្នេហាជាតិ វាជា មនោសញ្ចេតនា ច្រើនជាង ជាគំនិតនយោបាយ តែ វាអាចជំរុញសកម្មភាពច្រើនបែបយ៉ាងជាពិសេស នៅពេលសង្គ្រាម។

គេសន្មត់ថា វានៅក្នុងក្រុមគំនិត នៃអភិរក្សនិយម តែគួរកត់សំគាល់ថា របបសង្គមនិយមទាំងឡាយ ក្នុងសតវត្សទី ២០ តែងតែធ្វើការអំពាវនាវ ចំពោះ ភាពស្មោះត្រង់។ ដូចមានជាឧទាហរណ៍ នៅសហភាពសូវៀត នៅពេលសង្គ្រាមលោកលើកទី២ បានអំពាវនាវ សុំអោយប្រជាពលរដ្ឋ មានសេចក្តីស្នេហាជាតិ ដើម្បី ប្រមូលប្រជាកម្លាំង សំរាប់តស៊ូប្រឆាំងនឹងកងទ័ពអាឡឺម៉ង់។

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ខែ មេសា ឆ្នាំ ២០១៨**

នៅក្នុងបរិបទពិសេស, ស្នេហាជាតិ អាចប្រើជាស្លាក នៃគណបក្សនយោបាយ ដូចយ៉ាងមាននៅប្រទេសអង់គ្លេសនៅសតវត្សទី១៨ ដែលប្រើពាក្យ « អ្នកស្នេហាជាតិ » សំរាប់ចង្អុលបង្ហាញ នូវគោលលទ្ធិជាតិនិយម។ តែការប្រមូលផ្តុំពួកអ្នកស្នេហាជាតិបែបនេះ វាមិនដែលឋិតថេរ បានយូរនោះឡើយ។



វរសញ្ញករនៃប្រជាជាតិអាឡឺម៉ង់

# គំនិតជាតិនិយម អាឡឺម៉ង់ និង បារាំង

គួរលើកយកគំនិតជាតិនិយម នៃមស្ទឹមប្រទេសសំខាន់ៗ មកអធិប្បាយ នៅទីនេះដែរ ដូចយ៉ាង ប្រទេស អាឡឺម៉ង់ និង បារាំង។

## ប្រទេស អាឡឺម៉ង់

ប្រជាជាតិអាឡឺម៉ង់ កំណត់ដោយ ភាសា និង លក្ខណៈសម្ងូហភាពពិសេស ដែលត្រូវប្រមូល នូវកម្លាំងចេតសិក (force spirituel) និង រក្សារ៉ាប់រង នូវបេសកកម្មអរិយធម៌ នៃខ្លួន។ ការអប់រំ និង ការបញ្ចុះបញ្ចូល នាំអោយ ជនអាឡឺអ៉ង់ យល់ឃើញថា ប្រជាជាតិខ្លួន ជា « ការលាតផុតពីឯកត្តភាពផ្ទាល់ខ្លួនទៅទៀត » ដែលវាអនុញ្ញាតនឹង ធ្វើឲបានសម្រេច នូវសេរីភាព ហើយត្រូវតែបំរុងខ្លួន ធ្វើពលកម្មសំរាប់ការពារវា។

នៅក្នុងការសរសេរ របស់លោក Machiavel (១៨០៧) ស្ដីពីផ្ទាំង-នៃភាសាអាឡឺម៉ង់ (pan-germanisme) អាចចាត់ទុកបានថាជា នយោបាយប្រាកដនិយម (Real politik) និង ការចាំបាច់ នៃការស្ដាប់បង្គាប់របស់បុគ្គល ចំពោះមេខ្លួន។ លើអ្វីដែលទាក់ទង នូវការប្រាស័យទាក់ទង រវាងរដ្ឋនឹងរដ្ឋ « គឺមិនមាន ច្បាប់ និង សិទ្ធិ ទេ, មានតែមួយគត់ គឺ សិទ្ធិ នៃអ្នកខ្លាំង »។ ប្រជាជាតិនិមួយៗ មានទំនោរជា

ធម្មជាតិ « អាចលាយបញ្ចូលបាន នូវគ្រប់ជាតិសាសន៍ នៃមនុស្ស មកក្នុងប្រជាជាតិខ្លួន »។ ជនជាតិ អាឡឺម៉ង់ទាំងឡាយ ដើម្បីក្លាយទៅជា ប្រជាជាតិ ដែលមានប្រសិទ្ធភាព ត្រូវមាន អ្នកគរុកោសលជាតិ មានចរិកផ្តាច់ការ។ ការបង្ខំ តាមធាតុរបស់វា គឺធ្វើទៅតាម ទម្រង់ នៃការអប់រំ។ Zwingherr មានសេចក្តីថា « អ្នកនឹងយល់ខ្ញុំ នៅថ្ងៃមុខ អំពីមូលហេតុ ដែលខ្ញុំធ្វើនៅថ្ងៃនេះ »។ វិធី នៃមតិភាគច្រើន ក្នុងលទ្ធិប្រជាធិបតេយ្យ និង សាទិសនិច្ឆ័យ ឬទិសរួម (sens commun) វាបាត់អស់នៅចំពោះមុខគោលគំនិតនេះ ; « គ្មាននរណាម្នាក់ មានសិទ្ធិ វែកញែកទេ » និង នរណាម្នាក់ ដែលមាន ការយល់ដឹង ដ៏អស្ចារ្យបំផុត មាន សិទ្ធិបង្ខំ អោយអ្នករាល់គ្នា ធ្វើតាមការវិភាគរបស់គេ។

តែសព្វថ្ងៃ ប្រទេសអាឡឺម៉ង់ ក្លាយជាប្រទេសទំនើប និងប្រជាធិបតេយ្យសេរី ព្រោះជនអាឡឺម៉ង់ទាំងឡាយ គេនាំគ្នារួមកសាង ដើម្បីសេរីភាព និង នៅតែបំរុងខ្លួន ធ្វើពលកម្ម សំរាប់ការពារវាជានិច្ច។ គេយក លទ្ធិប្រជាធិបតេយ្យសេរី មកប្តូរនឹង អ្នកគរុកោសលជាតិ និង ជនផ្តាច់ការ តែគេនៅតែថែរក្សាគ្រឹះគោល នៃប្រជាជាតិអាឡឺម៉ង់ គឺភាសា និង លក្ខណៈ សម្ងហភាពពិសេស ដែលត្រូវប្រមូលនូវកម្លាំងចេតសិក ឬ កម្លាំងផ្លូវចិត្ត (force spirituel)

ដើម្បីធ្វើជាចលករជាតិ សំរាប់ធ្វើអភិវឌ្ឍន៍សេដ្ឋកិច្ច អោយបានរីកចំរើន ដែលនាំអោយប្រទេសគេ ក្លាយជាមគ្គុទេសក៏ នៅអឺរ៉ុប។

## ប្រទេស បារាំង

លោក Charles Maurras (១៨៦៨-១៩៥២) ជាអ្នកសារព័ត៌មាន និង អ្នកនយោបាយ បារាំងសែស ដែលគេទុកលោកជាអ្នកទ្រឹស្តី នៃជាតិនិយមទាំងមូល ក្នុងឋានៈលោក ជាប្រមុខ នៃចលនាជាតិនិយម មានឈ្មោះថា « action Française »។ លោក យល់ឃើញថា ជាតិនិយម ជាទស្សនៈនៃការរចនាសោភ័ណ្ឌ និង ប្រទេសបារាំង ជាប្រទេសដ៏វិចិត្រ និង តែមួយនៅក្នុងពិភពលោក។ ជាតិនិយម តាមលោក Maurras វាមាន គោលមនោវិញ្ញាណ ហើយ ប្រជាជាតិ នៅក្នុងន័យដាច់ខាត អាចចាត់ទុកដូចជា ទីបញ្ចប់នៅក្នុងខ្លួនវាផ្ទាល់។ ប្រទេសបារាំង ជា រាងកាយ, ព្រលឹង, សម្រស់ធម្មជាតិ។ ប៉ុន្តែ ព្រះទេពធីតា អាចនឹងវិនាសដូច្នេះ ព្រះនាង តម្រូវអោយមាន សក្ការៈ ឬ ទ្រនឹប ជាថិរកាល។ ដូច្នេះ ជាតិនិយមដាច់ខាត តម្រូវអោយ ទម្លាក់នូវគ្រប់លទ្ធិប្រជាធិបតេយ្យ ដែលវាអាច រំលាយប្រទេស, ហើយទង្វើនេះឯង ដែលទុកជាមូលហេតុ នៃស្នេហាជាតិនិយម ដែលនាំធ្វើអនុសាស អោយមាន របបនយោបាយ

នឹងនរ ដែលជារបបមិនមែនជា ការសម្តែងគំនិត នៃការផ្លាស់ប្តូររបស់មតិភាពច្រើន ដែលអាចដូរគំនិតបាន, ឬរបប ការពារផលប្រយោជន៍ពិសេស ; បើនិយាយអោយចំ, របបនឹងនរ គឺជា របបរាជានិយម។ ព្រះមហាក្សត្រ ព្រះអង្គជាអ្នកបំរើជាតិ, ជាតំណាង នៃឯកភាពជាតិ, អធិបតេយ្យជាតិ និង ចិរកាលភាពជាតិ។

ដើម្បីរក្សារស់រានមានជីវិត នៃប្រជាជាតិ, ត្រូវតែមាន ការការពារ ប្រឆាំងនឹង ពួកអ្នកឈ្លានពានបរទេស តែក៏ត្រូវប្រឆាំងនឹងសត្រូវផ្ទៃក្នុងដែរ។ សាធារណរដ្ឋ បានបោះបង់ចោល នូវមរតក នៃសាសនាកាតូលិកជាតិ ទៅអោយ សម្ព័ន្ធ ជាសត្រូវជាតិ បួនពួកគឺ - ពួកជនជាតិហ្សុីហ្វ, ពួកបរទេស, ពួកសមាគមហ្វ្រង់ម៉ាសុង និង ពួកកាន់សាសនាប្រូតេស្តង់។ មានតែ របបរាជានិយម ដែលអាច រំដោះប្រជាជាតិ អោយរួចផុតបានពី ពួកទាំងបួន ដែលយកប្រទេសបារាំង ធ្វើជារបស់ខ្លួន។ ហើយ មានតែ រាជរដ្ឋភិបាលតែមួយ អាចដោះស្រាយបញ្ហាសង្គម ដោយបញ្ចូល កម្មាជីព ទៅក្នុង សហគមជាតិ ក្នុងនាម នៃការផ្សះផ្សា នៃសម្មាជីព នឹងប្រជាជាតិ។ លោក Maurras និង បក្សពួកគាត់ ប្រឆាំងនឹង មូលធននិយម និង សេរីនិយម ដែលអោយចំណេញដល់ សាជីវកម្មនិយម។

តែគំនិត ជាតិនិយម របស់លោក Maurras វាគ្មានទទួលបាន ជោគជ័យនោះឡើយ នៅប្រទេសបារាំង។ ប្រទេសបារាំង បានឆ្លងកាត់ របបសាធារណរដ្ឋប្រាំដង ដែលជារបប នាំខ្លួន ដើរឆ្ពោះទៅរក ការរីកចំរើន នៃសេរីភាពក្នុងគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យ។ បាវចនា នៃសាធារណរដ្ឋបារាំង គឺ : សេរីភាព សមភាព ភាតរភាព។




លោក លន់ នល់ ប្រធានាធិបតី នៃ សាធារណរដ្ឋ (១៩៧២-៧៥)

# គំនិតជាតិនិយម និង ស្នេហាជាតិ នៅស្រុកខ្មែរ

ប្រជាជាតិខ្មែរ មានគោលគ្រឹះចម បីវត្ថុធាតុ: អំបូរ, ភាសា-អក្សរ និង ប្រវត្តិសាស្ត្រជាតិ។ វត្ថុធាតុទាំងបី មាន អត្ថភាពវាពិត ជារូបី និង អរូបី ផ្សំគ្នាជាតម្លៃចេតសិក (valeur spirituel) ផង និង តម្លៃសម្ភារៈផង។ អំបូរខ្មែរ មានស្នាមពិតប្រាកដនៅក្នុងប្រវត្តិសាស្ត្រ នៃមនុស្សជាតិ ហើយមាន លក្ខណៈពិសេស របស់ខ្លួន ខុសពីជាតិសាសន៍ ដទៃទៀត នៅក្នុងដំបន់រស់នៅរបស់ខ្លួន។ ជនខ្មែរអាច សំគាល់ មនុស្សខ្មែរដូចគ្នា បានងាយស្រួល ព្រោះមាន ភាវរូបទូទៅស្រដៀងគ្នា, របៀបរស់នៅ ជាប្រពៃណីតែមួយ, ជំនឿ ជាទំនៀមទម្លាប់ និង សាសនារួម។ គោលគ្រឹះ និង លក្ខណៈពិសេស ទាំងឡាយនេះឯង ដែលនាំអោយជនខ្មែរ ទាំងឡាយ មានសតិសម្បជញ្ញៈដោយចម្ងជាតិថា ខ្លួនមាន ភាពនៅរួម នៅក្នុងសហគមន៍ជាតិសាសន៍តែមួយ និង យកមកជាទីសំអាងថា ខ្លួនជាខ្មែរសុទ្ធ។ សតិសម្បជញ្ញៈរួម នេះ ជាគោលមូលដ្ឋាន នៃជាតិនិយមខ្មែរ មានតាំងពី បុរាណកាលមកម្លេះ។ តើ ជាតិនិយមខ្មែរ មានចរិតលក្ខ

ណៈជា រណសិរ្ស[1] ? តាមប្រវត្តិសាស្ត្រ ជាតិសាសន៍ខ្មែរ កសាងស្រុកខ្មែរ ទៅជាមហានគរ ដោយមាន រណជ័យ (ការច្បាំងឈ្នះ) លើសត្រូវ។ គុណសម្បត្តិ ដ៏ល្បីល្បាញ នៃព្រះមហាក្សត្រខ្មែរនៅសម័យនោះ គឺ រណក្សត្រ (ស្តេចសង្គ្រាម) ត្តួយ៉ាងព្រះបាទជ័យវរ្ម័នទី៧។ តើគេអាចចាត់ទុក ជាតិនិយមក្នុងលក្ខខណ្ឌនេះ ជា ចក្រពត្រនិយម បានដែរឬទេ ? ចក្រពត្រនិយម វាផ្តល់ នូវភាពពេញសិទ្ធិ នៃការច្បាំងដណ្តើមយកប្រទេសដទៃ មកដាក់ជា ប្រទេសចំណុះ។ នៅត្រង់ចំណុចនេះវាមានប្រយោជន៍ក្នុងការលើកឡើងពីលក្ខខណ្ឌសង្គ្រាម មាននៅក្នុងសម័យបុរាណខ្មែរ មកពិនិត្យដែរដូច សង្គ្រាមដឹកនាំដោយ ព្រះបាទ ហ៊ុន ទៀន (ដើមសតវត្សទី៣ នៃគ្រិស្តសករាជ) ដើម្បីបង្ក្រាប មេដឹកនាំកុលសម្ព័ន្ធរឹងរូសមួយចំនួន ដែលនៅតែមិនព្រម ទទួលស្គាល់រាជសក្តិរបស់ព្រះអង្គជាព្រះមហាក្សត្រ ប្រកាសដោយខ្លួនឯង។ សួរថា សម្តេង្ស ជាមួយព្រះនាង លិវ យី ជាមេកុលសម្ព័ន្ធធំមួយនៅស្រុកខ្មែរនៅសម័យនោះ វាផ្តល់សិទ្ធិស្វ័យប្រវត្តិ អោយ

---

1 រណសិរ្ស : ជួរនៃកងទ័ព ដែលរៀបចំត្រៀមខ្លួន ចាំឈមមុខបម្រុងប្រយុទ្ធនឹងបច្ចាមិត្តជាតិ។

ព្រះអង្គ, ជាជនបរទេស ជាអ្នកឈ្នះសង្គ្រាម, ប្រកាសនូវ អធ្យោត្តមភាព ឬ ភាពឧត្តមបំផុត (suprématie) នៃព្រះអង្គ លើមេកុលសម្ព័ន្ធ ទាំងអស់បានដែរឬទេ ? នៅក្នុង អធិករណៈបែបនេះ គេអាចឆ្លើយបានថា ទេ ព្រោះមេកុលសម្ព័ន្ធរឹងរូសទាំងនោះ គាត់ មានហេតុផលគ្រប់គ្រាន់ ដើម្បី បដិសេធ នូវអធ្យោត្តមភាពនោះ ដោយយកគោលការណ៍ ជាតិនិយមមកសំអាង។ ដូច្នោះ ព្រះបាទ ហ៊ុនទៀន ទោះបីព្រះអង្គ ចង់ ឬ អត់ ទ្រង់ក្លាយជា ជនចក្រពត្រ ព្រោះអំពើរបស់ព្រះអង្គ ជាអំពើចក្រពត្រ។ តែព្រះអង្គ ក៏មានគុណូបការៈមួយដែរ គឺជាអ្នកបង្កើត រាជានិយមខ្មែរ នៅលើគំរូហិណ្ឌូ ទោះបីព្រះអង្គ យកមធ្យោបាយចក្រពត្រ មកប្រើ ក៏ដោយ ដើម្បីស្ថាបនា នូវរដ្ឋទំនើបតែមួយនៅសម័យនោះ ឈ្មោះថា ហ្វូណន ទុកវាជា រណអាវុធផង អាវុធចេតសិកផង នៃជាតិនិយម ។ ជនខ្មែរ ភាគច្រើន ទទួលយល់ព្រម ព្រោះ មើលឃើញអត្ថប្រយោជន៍ នៃរបបរាជានិយម ជាង របបកុលសម្ព័ន្ធ ព្រោះវាជារបបផ្ដល់នូវមូលដ្ឋានជាតិពិតប្រាកដ និង តែមួយគត់ សំរាប់ការពារជាតិសាសន៍ខ្មែរ។ រាជានិយមនេះឯង ជាថ្នាល បណ្ដុះ នូវសតិសម្បជញ្ញៈ នៃជាតិនិយម ផ្អែកលើជាតិសាសន៍ដែលមានអំបូរសភាគពិតប្រាកដ។

នគរហ្វូណន ឬ អាណាចក្រភ្នំ ត្រូវបាន នគរ ចេនឡា ជានគរធ្លាប់ចំណុះខ្លួន វាយដណ្តើមយកបាន រវាងឆ្នាំ ៥៧៥ នៅក្នុងរាជ្យ ព្រះបាទភវវរ្ម័ន (៥៥០-៦០០)[2] ហើយ ដាក់បញ្ចូល អោយទៅជានគរតែមួយ ជាចេនឡាធំ។ តែ ចេនឡា ក៏ជារដ្ឋ បង្កើតឡើង នៅលើគំរូហិណ្ឌូ ដូច ហ្វូណនដែរ ហើយ ព្រះរាជវង្សានុវង្ស ក៏មានខ្សែញាតិវង្ស ជាមួយញាតិវង្ស នៃ ហ្វូណន ដែរ។ ដូច្នេះ អាចចាត់ជា ជម្លោះ រវាង ព្រះរាជវង្សានុវង្ស ពីរវង្សខុសគ្នា។ វង្សទី១ ជាសោមវង្ស តាំងព្រះរាជធានីនៅ វ្យាធបុរះ សព្វថ្ងៃ អង្គរបុរី ស្រុកព្រៃកប្បាស ខេត្តតាកែវ។ វង្សទី២ ជាសូរ្យវង្ស តាំងប៉ែកខាងលើ នៅ លម្ពបុរះ សម្បូណ៌។ តាមលោក Bernard Philippe Groslier : ហ្វូណន ជួបប្រទះនឹងមហន្តរាយធម្មជាតិ មកពីទឹកជំនន់ បំផ្លាញសេដ្ឋកិច្ចជាតិ ហើយ បង្ខំអោយប្រជារាស្ត្រ ភៀសខ្លួនទៅរស់នៅត្រង់ដីខ្ពស់ នៅភាគខាងជើង ក្នុងដែនដីចេនឡា ហើយដែលនាំអោយស្តេច ចេនឡា ឆ្លៀតឱកាសនេះ វាយយកហ្វូណន ដើម្បីបង្កើត រាជាណាចក្រខ្មែរថ្មី។

---

[2] ព្រះបាទ ភវវរ្ម័ន ជាបុត្ររបស់ព្រះបាទវីរវរ្ម័ន និង ជាចៅរបស់ព្រះបាទ រុទ្រវរ្ម័ន (៥១៤-៥៣៩) ដែលជាមហាក្សត្រខាងនគរភ្នំ (ហ្វូណន)។

ដូច្នេះ សង្គ្រាម ដឹកនាំដោយព្រះបាទភវវរ្ម័ន អាចចាត់ទុកជា សង្គ្រាមវាតទីសុទ្ធសាធ។ តែសង្គ្រាមនេះ មិនបានសើរើ លក្ខខណ្ឌ នៃជាតិនិយមខ្មែរនោះឡើយ ព្រោះប្រជារាស្ត្រ ហ្វូណនក្តី ចេនឡាក្តី មានអំបូរតែមួយ គឺ ខ្មែរ-មន។ ជាតិនិយមខ្មែរ នៅសម័យនោះ វាគ្រាន់ជាអារម្មណ៍ នៃភាពនៅរួម ក្នុងអំបូរតែមួយ ព្រោះស្រុកខ្មែរ គ្មានការកំហែង ពីប្រទេសជិនខាង ជាសត្រូវនោះឡើយ លើកលែងតែប្រទេសចិន[3] ជាមហាប្រទេសនៅអាស៊ី។ ដូច្នេះ សង្គ្រាមទាំងឡាយកើតមាននៅក្នុងសម័យបុរាណខ្មែរ ច្រើនជា សង្គ្រាម ឬក៏ វាតទី ឬក៏ ផ្ទៃក្នុង ដើម្បីរក្សាសណ្តាប់ធ្នាប់ ព្រោះស្រុកខ្មែរ ជាវិភូ[4]ប្រទេស ហើយ ស្តេចខ្មែរ ពូកែពូរាងធ្វើសង្គ្រាម នៅក្នុងដំបន់។ ប្រទេស ដែលទទួលការឈ្លានពានញឹកញយ ពីសំណាក់ស្រុកខ្មែរ គឺចម្ប៉ា[5] ព្រោះជា ប្រទេស

---

3 ក្នុងរាជ្យព្រះបាទ ហ្វាន់ស៊ីយុន (២៥០ ក្នុង គ.ស.) មានការចងស្ពានមេត្រីនឹងប្រទេសចិន ដើម្បីការពារសន្តិភាពក្នុងប្រទេស។
4 វិភូ : ឬទ្ធាចេស្តាក្តុំថ្កើងខ្លាំង។
5 ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន (៤៨៥-៥១៤) បានរឹតចំណងមេត្រីរវាងចិន អោយកាន់តែមាំមួន ដើម្បី ធ្វើសង្គ្រាមជាមួយប្រទេស

មាន ព្រំដែនរួមជា មួយស្រុកខ្មែរ។ តែក្រោយមក ប្រទេសចាម ក៏តែងតែលើកទ័ព មកច្បាំងនឹងស្រុកខ្មែរជាច្រើនដងដែរ[6]។

គំនិតជាតិនិយមខ្មែរ វាមានលក្ខណៈច្រើនជា ស្នេហាជាតិ ព្រោះជា មនោសញ្ចេតនា ច្រើនជាងជា គំនិតនយោបាយ ព្រោះនយោបាយ ជាកិច្ចការផ្តាច់មុខរបស់ព្រះមហាក្សត្រ។ តែ ព្រះមហាក្សត្រ តែងតែ យកគំនិតស្នេហាជាតិ មកធ្វើជាមធ្យោបាយ នៅពេលសង្គ្រាម ព្រោះព្រះអង្គ ត្រូវការប្រជាកម្លាំង ដើម្បីធ្វើសង្គ្រាម ក្នុងគោលដៅយ៉ាងណាក្តី។ បើជា សង្គ្រាមស៊ីវិល គំនិតស្នេហាជាតិ គឺ វាអាចគ្រាន់តែជា ការជំពាក់ចិត្ត ទៅលើដំបន់មួយ, កន្លែងមួយ ឬ លំនាំ

---

ចាម និង ប្រទេសជិនខាងនៅទិសខាងកើត យកមកធ្វើជាប្រទេសចំណុះ។

6 នៅក្នុងរាជ្យព្រះបាទសុរិយាវរ្ម័នទី១ (១០០២-១០៤៩) ស្តេចអង្គនេះ បានចងសម្ពន្ធ ជាមួយប្រទេសចិន និង ចម្បា ដើម្បី រួមកម្លាំង ការពារកងទ័ពយួន ដែលគេ ប្រថ្នានឹងឈ្លានពានស្រុកចាម និង ខ្មែរ ដើម្បីវាតទឹកដី។ ពេលនោះ យួនបានមកតាំងទីលំនៅ នៅត្រង់ដំបន់ខាងជើងប្រទេសចាម គឺត្រង់តុងកឹងសព្វថ្ងៃ។

នៃជីវិតមួយ, ព្រះមហាក្សត្រ ឬ បុគ្គល ជាអ្នកដណ្ដើមរាជ្យ និង មិនចាំបាច់បញ្ចូល គំនិតអរូបី នៃប្រទេស។ បើជាសង្គ្រាមរ៉ាតទី ព្រះមហាក្សត្រ ព្រះអង្គ តម្រូវ នូវកាតព្វកិច្ច នៃប្រជារាស្ត្រគឺ ចូលធ្វើទាហាន ដើម្បីបំរើ ព្រះរាជមហិច្ឆិតា។ បើជាសង្គ្រាម ប្រឆាំងនឹងបរទេសប្លន់[7] នៅក្នុងលក្ខខណ្ឌនេះ ប្រជារាស្ត្រខ្មែរ គ្មានជំរើសនឹងមិនចូលរួមការពារដែនដីជាតិនោះឡើយ ក្នុងកាតព្វកិច្ចខ្លួន ជាអ្នកបំរើព្រះមហាក្សត្រ។

ជនខ្មែរទាំងឡាយ ច្រើនប្រើពាក្យ ស្នេហាជាតិ ជាង ជាតិនិយម។ ស្នេហាជាតិ ជាអារម្មណ៏ រីឯ ជាតិនិយម វិញជាសកម្មភាពនយោបាយ។ សកម្មភាព ជាសិទ្ធិ ដែលមានច្បាប់ការពារ។ រហូតមកដល់ឆ្នាំ ១៩៤៧ ស្រុកខ្មែរ គ្មានច្បាប់ សំរាប់ការពារសិទ្ធិប្រជាពលរដ្ឋនោះឡើយ។ រដ្ឋធម្មនុញ្ញខ្មែរទី១ បានចូលជាធរមាននៅឆ្នាំ ១៩៤៧ តែការអនុវត្តន៏វិញ បានជួបប្រទះ នូវបញ្ហាច្រើនណាស់ កើតចេញមកពី ការគ្មានទម្លាប់ផង ពីការប្រឆាំង ពីព្រះមហាក្សត្រផង និង អាជ្ញាធរបារាំងមានសល់នៅស្រុកខ្មែរផង ជា

---

[7] បរទេសប្លន់ : បរទេសជាអ្នកឈ្លានពាន។

ពិសេសវិស័យសន្តិសុខជាតិ។ តែចាប់ពីឆ្នាំ ១៩៣៦ គំនិតជាតិនិយម ចាប់មានពន្លក នៅក្នុងមជ្ឈដ្ឋាន នៃអ្នកចេះដឹង។ អ្នកទាំងនោះ មានចំនួនតិចពិត តែមានឈ្មោះដ៏រុងរឿង ដូចជា លោក អៀវ កើស សឺង ង៉ុកថាញ់, ព្រះតេជគុណ ហែម ជៀវ ។ល។ ចំនួន តិចពិត តែសកម្ម នាំគ្នាគិតពិចារណាអំពីប្រភព នៃអកុសលខ្មែរ ដោយសារអាណានិគមបារាំង ដោយមាន ជំនឿជាក់ច្បាស់ថា បើសិនជាប្រជាពលរដ្ឋខ្មែរ មានមនសិការជាតិ ហើយនាំគ្នាក្រោកឡើង ដើម្បី រំដោះខ្លួន វានឹងអាចធ្វើបាន ដោយផ្អែកលើគំនិតសំខាន់បីយ៉ាង :

- អនាគតជាតិខ្មែរ វាស្ថិតនៅក្នុងដៃប្រជាពលរដ្ឋខ្មែរ ;
- ប្រពៃណីជាតិ វាមានតម្លៃជាតិជាង ម៉ូតបរទេស ;
- ប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន វាគ្រាន់តែជាស្រមោល នៃអាណានិគមបារាំង នៅឥណ្ឌូចិន។

ត្រូវដឹងថា នៅឆ្នាំ ១៨៨៧ បារាំង បានបញ្ចូលស្រុកខ្មែរ ទៅក្នុង សហព័ន្ធឥណ្ឌូចិន ដែលគេបង្កើត ដោយបំពានលើសន្ធិសញ្ញា នៃអាណាព្យាបាល ខ្មែរ-បារាំង។ ទង្វើនេះ វាប្រឆាំងនឹងផលប្រយោជន៍ខ្មែរ ព្រោះតទៅមុខ ស្រុក ខ្មែរស្ថិតនៅក្រោម ស្រុកយួន ដែលបារាំងគេទុកជា វត្ថុធាតុចម នៃអាណានិគម នៅសហព័ន្ធឥណ្ឌូចិន។ ដូច្នេះ ដែនដី

កម្ពុជាក្រោម ត្រូវបានបារាំង គេបំបែកពីស្រុកខ្មែរ យកទៅបញ្ចូល ក្នុងអាណាចក្រកូសាំងស៊ិន ដែលបារាំង គេទុកជាឯកភាពមួយ នៃស្រុកយួន (តុងកឹង, អណ្ណាម, និង កូសាំងស៊ិន)។

បំផុស នូវមនសិការជាតិ ពួកអ្នកចេះដឹងខ្មែរទាំងនោះមានជំនឿថា នឹងអាចបង្កើតបាន តាមការផ្សាយ នូវគំនិតជាតិនិយម។ ដូច្នេះ ត្រូវបង្កើតសារព័ត៌មាន (ឈ្មោះអង្គរវត្ត) ដើម្បី លើកកម្ពស់ ការយល់ដឹង ជាសាធារណៈ អំពីបញ្ហានេះ។ នៅពេលនោះ គំនិតជាតិនិយម ត្រូវប្រមូលគ្រប់កម្លាំង នៃបញ្ញាជាតិ គឺ រាជានិយម ជាតំណាង នៃប្រពៃណី, ពុទ្ធសាសនា ជាតំណាង នៃប្រជារាស្ត្រ និង អ្នកចេះដឹង ជាតំណាង នៃវប្បធម៌ជាតិ ហើយទាំងអស់រួម ជាកម្លាំងចលករ នៃអ្នកជាតិនិយម ហ៊ានដើបតស៊ូ ទាមទារឯករាជ្យជាតិ ពីអាណានិគមបារាំង។ ព្រលឹង នៃជាតិនិយមខ្មែរ នៅឆ្នាំ ១៩៣៦ វាធ្លាប់មាន ស្នាមគំនូរបង្ហាញជាច្រើននៅក្នុងប្រវត្តិសាស្ត្រជាតិ អំពីការតស៊ូខ្មែរទប់ទល់នឹងការឈ្លានពាន នៃប្រទេសសៀម ហើយស្នាមដែលមានកេរ៍ឈ្មោះល្បីល្បាញជាងគេ គឺ ការវាយកំចាត់សៀមចេញពីស្រុកខ្មែរ របស់ព្រះបាទពញាយ៉ាត (១៤២១-១៤៦២) ដើម្បីឯករាជ្យជាតិ។ មួយវិញទៀត មេទ័ពខ្មែរ ដែលទប់ទ័ពសៀម មិនអោយ នៅត្រួតត្រាស្រុកខ្មែរបាន ក្រោយពីទ័ព

សៀមវាយបែកបន្ទាយលង្វែក នៅឆ្នាំ ១៥៩៣ គឺ រាមាជើងព្រៃ។ ក្រោយទទួលបាន ជ័យជំនះហើយ លោកក៏ឡើងសោយរាជសម្បត្តិ មាន ព្រះនាមរាជ្យថា ព្រះបាទរាមាជើងព្រៃ (១៥៩៤-១៥៩៦)។ តែគុណូបការៈ របស់ព្រះអង្គមិនមានកំទរ នៅក្នុងប្រវត្តិសាស្ត្រខ្មែរនោះទេ ព្រោះ ព្រះអង្គ គ្មានដើមកំណើត នៃគ្រួសាររាជវង្ស ដែលជាមូលហេតុអោយមាន ការជំទាស់លាក់មុខពីមន្ត្រី ស្មោះនឹង រាជវង្សចាស់មួយក្រុមតូច នាំគ្នាលួចទៅពឹង ជនជាតិពរទុគ្កេស៍ និង អេស្ប៉ាញ៉ូល ឈ្មោះ Diego Belloso និង Blas Ruis នាំសេនា ២៤ នាក់ មកធ្វើឃាត ព្រះបាទរាមាជើងព្រៃបាននៅក្នុង ព្រះបរមរាជវាំងតែម្តង ដោយប្រើល្បិច បោកបញ្ឆោតព្រះអង្គ។ បន្ទាប់មក ក៏នាំគ្នាលើក ព្រះរាជបុត្រទី២របស់ព្រះបាទសត្ថាទី១ (១៥៦៧-១៥៧៥)[8] ព្រះនាម ពញាតន់ អោយឡើងសោយរាជសម្បត្តិ (១៥៩៤-១៥៩៧)។ ព្រះ

---

[8] ព្រះរាជបុត្រទី១ របស់ព្រះសត្ថាទី១ ព្រះនាមព្រះបាទជ័យជេដ្ឋាទី១ បានសោយរាជសម្បត្តិ បន្តព្រះមាតាព្រះអង្គនៅបន្ទាយលង្វែក (១៥៧៥-១៥៩៣)។ នៅពេលទ័ពសៀមវាយបន្ទាយលង្វែក ព្រះរត់ភៀសខ្លួនចេញពីបន្ទាយរួច ទៅគង់ឯខេត្តស្ទឹងត្រែង ហើយក៏សុគតនៅទីនោះ។

មហាក្សត្រខ្មែរ បន្តៗមក បានធ្វើសង្គ្រាម ប្រឆាំងនឹងកងទ័ពបរទេសដែរ តែជាសង្គ្រាមការពាររាជបល្ល័ង្ក ព្រោះព្រះអង្គ តែងតែទៅពឹងបរទេស ជូនសៀម ជូនយួន មកជួយព្រះអង្គ។ រហូតមកដល់ រាជ្យព្រះបាទអង្គដួង (១៨៤១-១៨៦០) ទើបបញ្ចប់ នូវជម្លោះ នៅក្នុងព្រះរាជវង្សានុវង្ស ដោយសារ សៀម និង យួន គេយល់ព្រមគ្នា ឈប់ច្បាំងដណ្តើមយកស្រុខ្មែរ ហើយលើកព្រះអង្គដួង អោយឡើងសោយរាជសម្បត្តិ តែគេទុក រាជ្យរបស់ព្រះអង្គ ជាសហជីវិតរាជ្យ (condominium) របស់ប្រទេសគេ។ នៅក្នុងរាជ្យព្រះបាទនរោត្តម (១៨៦០-១៩០៤) ស្រុកខ្មែរ មានការបះបោរមួយចំនួន ប្រឆាំងនឹង បារាំង តួយ៉ាង មេបំបះបោរ ឈ្មោះ អាចារ្យ ស្វា, ពោធិកំបោរ, ស្នងសូរ និង មនោកែវ[9]។ នៅក្នុងប្រវត្តិសាស្ត្រខ្មែរ គេចាត់ទុក ឧទ្ទាមកម្មនោះ ជាអំពើក្បត់នឹង ព្រះមហាក្សត្រ។ តែការបះបោរទាំងឡាយនោះ ទោះបីទទួលបរាជ័យក៏ដោយ តែវានាំអោយបារាំង

9 ការបះបោរ របស់ ស្នងសូរ និង មនោកែវ ជាការបះបោរនៅក្រោមកម្លាំង ជម្រុញចិត្ត អោយធ្វើ របស់ព្រះស៊ីវត្ថា ជាអនុជព្រះបាទនរោត្តម ព្រោះទ្រង់ តវ៉ាមិនព្រមទទួលស្គាល់ការឡើងសោយរាជសម្បត្តិ របស់ព្រះជេដ្ឋា។

បន្ទុយ ការក្រអឺតក្រអោង របស់គេជាច្រើន នៅស្រុកខ្មែរ ដើម្បីជៀសវាង រានទីទៅលើទំនៀមខេមរជាតិ។

យុទ្ធនាការ របស់សម្តេច សីហនុ នៅឆ្នាំ ១៩៥៣ ដើម្បីទាមទារឯករាជ្យ ពីបារាំង ដែលមានឈ្មោះថា « ព្រះរាជបូជនីយ៍កិច្ច សម្រាប់ឯករាជ្យកម្ពុជា » ជាទ្រឹស្តី ក្នុងគំនិតជាតិនិយម យកមកប្រើជា មធ្យោបាយនយោបាយ សំរាប់ប្រមូលកម្លាំងជាតិ គ្រប់និន្នាការនយោបាយ និង ប្រជាពលនិកាយ និង កងជីវពល ដើរឆ្ពោះទៅរកទិសតែមួយគឺការតស៊ូ ដើម្បីឯករាជ្យជាតិ។ ត្រូវដឹងដែរថា គំនិតនេះដើមឡើយ ជាគំនិត របស់គណបក្សឈ្មោះឆ្នោតគឺ គណបក្សប្រជាធិបតេយ្យ នៅឆ្នាំ ១៩៤៦ ទាមទារឯករាជ្យភ្លាមពីបារាំង ដោយបដិសេធដាច់ខាត មិនព្រមបញ្ចូលស្រុកខ្មែរទៅក្នុងសហភាពបារាំង ដែលបារាំងគេបង្កើតថ្មី សំរាប់ប្តូររូបភាព នៃអាណានិគម របស់គេនៅឥណ្ឌូចិន និង អាហ្វ្រិកទ្វីប ក្រោយពីសង្គ្រាមលោកលើកទី២។ គំនិតទាមទារឯករាជ្យភ្លាមនេះឯង នៅពេលនោះ វាជាគំនិតផ្ទុយស្រឡះពី ព្រះរាជហឫទ័យ នៃសម្តេច សីហនុ ព្រោះព្រះអង្គ ក្នុងនាមជា ព្រះមហាហក្សត្រ បានចុះហត្ថលេខា យល់ព្រមភ្លាម បញ្ចូលស្រុកខ្មែរ ទៅក្នុងសហភាពបារាំង តែហត្ថលេខានោះ ត្រូវបានរដ្ឋសភា ដែលមានគណបក្សប្រជាធិបតេយ្យ ជាគណបក្សភាគច្រើនដាច់ខាត និង កាន់អំណាច

មិនដែលអោយសច្ចាប័ន។ ការណ៏នេះឯង ជាដើមហេតុនៃទំនាស់ចេញមុខ រវាង គណបក្សប្រជាធិបតេយ្យ និង ព្រះមហាក្សត្រ នរោត្តម សីហនុ។ ត្រូវដឹងបន្ថែមទៀតថា គណបក្សប្រជាធិបតេយ្យ មានផែនការ បីយ៉ាងគឺ ទី១ ទាមទារឯករាជ្យជាតិ ពីបារាំង, ទី២ ទាមទារអោយបញ្ចូលកម្ពុជាក្រោម មកក្នុងកម្ពុជាវិញ និង ទី៣ ទប់ទល់ ទុកជាមុន នូវឥទ្ធិពល នៃចលនាកុម្មុយនិស្តយួន នៅស្រុកខ្មែរ។ ផែនការនេះឯង ដែលបារាំង គេទុក គណបក្សប្រជាធិបតេយ្យ ជាសត្រូវនឹងគេ ហើយគេយកសម្តេច សីហនុ ជាកូនរែករបស់គេ ដើម្បីលេង ប្រឆាំងចេញមុខនឹងគណបក្សប្រជាធិបតេយ្យ។ ដូច្នោះ គំនិតជាតិនិយម របស់សម្តេច សីហនុ នៅពេលនោះ វាគ្រាន់តែសំរាប់ បំរើផលប្រយោជន៏ផ្ទាល់ របស់ព្រះអង្គផង និង ផលប្រយោជន៏បារាំងផង ដែលវានាំបង្កើត នូវបរិយាកាសនយោបាយ ខ្មៅងងឹត នៅស្រុកខ្មែរ។ ពួក ប៉ូលិស សម្ងាត់ បារាំងសែស បាន ប្រើល្បិច បង្កើត ចលនា « នាគខ្មៅ » សំរាប់ប្រឆាំងនឹង ពួកអ្នកប្រឆាំងនឹង អំណាច អាណ្ណាចរ អាណានិគមគេ ដូចយ៉ាង ការចាប់ សមាជិកគណបក្សប្រជាធិបតេយ្យ ជាច្រើន ដាក់គុក អ្នកខ្លះទៀត ត្រូវគេធ្វើទារុណកម្ម អ្នកខ្លះទៀត ត្រូវ គេ បញ្ជូន ទៅឃុំ នៅមណ្ឌល ប៉ូលូកុងឌ័រ ជាគុកសំរាប់ជនឧក្រិដ្ឋ ។ វិធានការ បង្រ្កាប របស់ បារាំង និង

សីហនុ ចំពោះ អ្នកប្រឆាំង កើនកំរិតខ្លាំងឡើងៗជានិច្ច រហូតនៅ ថ្ងៃ ទី១៤ មករា ឆ្នាំ១៩៥០ មានការធ្វើឃាត ដោយមាន ការចោលគ្រាប់បែកដៃពីជនម្នាក់ ទៅក្នុង ការិយាល័យ របស់លោក អៀវ កើស ជាអតីតប្រធានរដ្ឋ សភា និង ជាអគ្គលេខាធិការ នៃគណបក្សប្រជាធិបតេយ្យ បណ្តាលអោយលោក ស្លាប់ភ្លាមនៅទីកន្លែង។ ឃាតកម្ម នយោបាយនេះ ធ្វើឲមាន ការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅ ស្រុកខ្មែរ ក្នុង មតិមហាជន ដែលគេមានជំនឿថា វាជា ស្នា ដៃ របស់ហ្លួង សីហនុ តែម្តង ព្រោះ ទ្រង់ស្អប់ផង និង ច្រណែនផងនឹង ប្រជាប្រិយភាព នៃគណបក្សប្រជាធិប តេយ្យ។ តែ ក្រោយ បន្តិច មក ប៉ូលិស បាន ផ្តល់ ព័ត៌មាន ថា គេចាប់បានឃាតករ ឈ្មោះ នូយ៉ា ជា សមាជិក នៃ គណបក្សសេរីភាព, តែអ្នកភ្នំពេញ នាំគ្នាខ្សឹបខ្សៀវថា រឿងហ្នឹង ជា រឿង ស្ថិតភ្នែក សុទ្ធសាត ព្រោះ វា គ្មានហេតុ ផលអ្វីបន្តិចទាល់តែសោះ ដែលនាំឲ គណបក្សសេរីភាព ធ្វើ ឃាត លោក អៀវ កើស។ តែទោះបីយ៉ាងណា ក៏គេនៅ តែទុកឃាតកម្មនេះ ជា ឃាតកម្មនយោបាយ គឺ មាន ប្រភពចេញពី ជម្លោះ រវាង សីហនុ នឹងគណបក្សប្រជាធិប តេយ្យ ព្រោះទ្រង់ មិនពេញចិត្តនឹង របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ ហើយទ្រង់ ក៏មិនយល់ស្របផងដែរ នឹង គោលនយោបាយ របស់រាជរដ្ឋាភិបាល ដឹកនាំដោយ

គណបក្សប្រជាធិបតេយ្យ ដែល មាន ទស្សនៈ ផ្ទុយស្រឡះពីព្រះអង្គ គឺ សេរីនិយម និងទាមទារឯករាជ្យជាតិ ជាបន្ទាន់ពីអាណានិគមបារាំង។ ដូច្នោះ សម្ដេច សីហនុ ព្រះអង្គតែងតែទុកគំនិតជាតិនិយមជា វាក្យសព្ទ មានវេរចនៈនឹងសត្រូវនយោបាយ របស់ព្រះអង្គ។ ដូច្នេះ ព្រះអង្គ តែងតែប្រើពាក្យ « រាស្ត្រនិយម » ជំនួសវិញតួយ៉ាងព្រះអង្គ ប្រទានឈ្មោះ ចលនានយោបាយ របស់ទ្រង់ថា « ចលនាសង្គមរាស្ត្រនិយម »។

ព្រឹត្តិការណ៍ថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០ បំផុស នូវគំនិតជាតិនិយម ក្នុងគោលដៅការពារ នូវបូរណភាពដែនដីជាតិ ពីការឈ្លានពាន ពីសំណាក់កងទ័ពយួនកុម្មុយនិស្ត។ ជាថ្មីម្ដងទៀត សម្ដេច សីហនុ ទ្រង់ប្រឆាំងជាដាច់ខាត រហូតដល់ទៅធ្វើការអំពាវនាវ សុំអោយកងទ័ពកុម្មុយនិស្តយួនជាកម្លាំងបរទេស វាយប្រហារ កងទ័ពជាតិខ្មែរ ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួន គឺអំណាចផ្ដាច់ការ។ ទង្វើនេះឯង ដែលនាំអោយមានកំណើត នៃសាធារណរដ្ឋខ្មែរបង្កើតឡើង ដើម្បី ការពារជាតិ នៅក្នុងគំនិតជាតិនិយម និង ស្នេហាជាតិ។

របបសាធារណរដ្ឋ នៅពេលនោះ ប្រើ គំនិតជាតិនិយម ទុកជា នយោបាយការពារជាតិ និង ស្នេហាជាតិ ទុកជា

ស្មារតីរួម នៃប្រជាពលរដ្ឋ តស៊ូប្រឆាំងនឹងកងទ័ពយួនកុម្មុយនិស្ត។ ជាតិនិយម រួមនឹង ស្នេហាជាតិ វាជាកម្លាំងសង្គហការណ៍ នៃជាតិខ្មែរ ដែលរងគ្រោះ ពីអត្តូទត្តភាពរបស់ស្តេចសីហនុ ដែលនាំអោយយួនកុម្មុយនិស្ត គេយកមកប្រើ ដើម្បីរក ផលប្រយោជន៍ របស់គេ រហូតមកដល់សព្វថ្ងៃនេះ។

ជាតិនិយមខ្មែរ ត្រូវបានប្រវត្តិសាស្ត្រខ្មែរ តាមរបៀបបកស្រាយជាផ្លូវការ ប៉ះប៉ែរទៅរកតម្លៃ នៃរាជានិយម ដែលនាំអោយប្រវត្តិសាស្ត្រ មានលក្ខណៈចម ជាព្រះរាជពង្សាវតា ឬប្រវត្តិ នៃព្រះរាជវង្សានុវង្ស ក្នុងនោះ គេបង្ហាញតែគុណូបការៈសំខាន់ នៃព្រះមហាក្សត្រ។ ដូច្នេះ ជាតិនិយម វារលាយទៅក្នុង រាជានិយម ដែលនាំលេចឡើង នូវគំនិតជាតិនិយម គឺ ព្រះមហាក្សត្រ និង ស្នេហាជាតិ គឺ ស្នេហាព្រះមហាក្សត្រ។ គំនិតនេះ វាលើសពីគោលគំនិត នៃកំណោត ឬ សក្ការៈ នៃបុគ្គល[10] ទៅទៀត ព្រោះ ព្រះមហាក្សត្រ ព្រះអង្គគឺជាសុកល (le roi est tout)។ ព្រះរាជាគ្រប់អង្គ តែងតែយក លក្ខណៈពិសេសនេះ មកបកស្រាយ សម្រាប់ទៅ

---

[10] Culte de personnalité.

តាមផលប្រយោជន៍ របស់ព្រះអង្គរៀងៗខ្លួន។ រីឯគំនិតជាតិនិយម គ្រប់ហ្លួង តែងតែចៀសវាងអោយតម្លៃវា ព្រោះ តម្រូវអោយព្រះអង្គ ចែកប្រជាជាតិ ជាមួយប្រជារាស្ត្រ ព្រោះជាតិនិយម ជាសិទ្ធិ នៃបុគ្គល ហើយ សិទ្ធិ ត្រូវមាននីតិបញ្ញាតិ ដែលជាអត្តភាព ប្រឆាំងនឹង រាជអំណាច។ ដូច្នេះ ព្រះមហាក្សត្រ ជាទូទៅ ព្រះអង្គ ចូលចិត្ត រំឭក នូវគំនិតស្នេហាជាតិ នៅពេលដែលព្រះអង្គត្រូវការ ប្រជាពលនិកាយ សំរាប់ធ្វើសង្គ្រាម បំរើរាជសម្បត្តិ ព្រោះស្នេហាជាតិ វាជា អារម្មណ៍មានកំណត់ និង តាមទេសកាល របស់បុគ្គលម្នាក់ៗផ្ទាល់ខ្លួន ហើយកម្លាំងរួមនោះ វានឹងរលាយបាត់ទៅវិញ នៅពេលណា ដែលគ្មានអ្នកណាម្នាក់ ជាអ្នកប្រមូល។ ដូច្នេះ គំនិតស្នេហាជាតិ ជាទូទៅ ជា ឧបករណ៍នយោបាយ របស់អំណាចនយោបាយ រីឯ គំនិតជាតិនិយមវិញ វាជាខ្លឹមសារជាតិ នៅក្នុងនីតិរដ្ឋ៕